របៀបដំឡើង ពុម្ពអក្សរយូនីកូដខ្មែរ លើប្រព័ន្ធដំណើរការ Windows XP

១. របៀបនៃការដំឡើង

- សូមចុចពីរដង(Double Click) លើ ឯកសារ «KhmerUnicode2.0.1.exe» ដើម្បីចាប់ផ្តើម ដំឡើងពុម្ពអក្សរយូនីកូដខ្មែរ



- បន្ទាប់មក សូមចុចលើប៊ូតុង «Next»

- សូមចុចលើប៊ូតុង «Next» ម្តងទៀត



- ពុម្ពអក្សរយូនីកូដខ្មែរកំពុងដំឡើង សូមរង់ចាំរហូតដល់ការដំឡើងត្រូវបានបញ្ចប់



ករណីពិសេសសម្រាប់ម៉ាស៊ីនកុំព្យូទ័រមួយចំនួន ៖

- ប្រសិនបើលោកអ្នកឃើញផ្ទាំងដូចក្នុងរូបខាងក្រោម សូមចុចលើប៊ូតុង «OK»



- បន្ទាប់មក សូមចុចលើប៊ូតុង «Browse»



- សូមជ្រើសរើសយក Folder មួយដែលមានឈ្មោះថា «i386»



ចំណាំ៖ លោកអ្នកអាចស្វែងរក Folder «i368» បានពី CD «Windows XP Professional Service Pack 2»

- បន្ទាប់មក សូមចុចលើប៊ូតុង «Open» រួចសូមចុចលើប៊ូតុង «OK»



- ការដំឡើងពុម្ពអក្សរយូនីកូដខ្មែរបានបញ្ចប់ សូមចុចលើប៊ូតុង «Finish»

ចំណាំ៖ បន្ទាប់ពីដំឡើងពុម្ពអក្សរយូនីកូដខ្មែររួចហើយ សូមដំណើរការកុំព្យូទ័រឡើងវិញ (Restart the Computer)

២. កំណត់សម្គាល់បន្ថែម សម្រាប់ប្រព័ន្ធដំណើរការ Windows XP

ដើម្បីឲ្យកម្មវិធី Microsoft Office XP, Office 2003 ឬ Office 2007 អាចប្រើប្រាស់ពុម្ពអក្សរយូនីកូដខ្មែរ បានដោយរលូន បន្ទាប់ពីលោកអ្នកបានដំឡើងពុម្ពអក្សរយូនីកូដខ្មែរ នោះលោកអ្នកត្រូវថតចម្លងឯកសារ ដែលមានឈ្មោះថា «USP10.dll» ទៅដាក់ក្នុង Folder ដូចខាងក្រោម ៖

ចំពោះ Office XP => C:\Program Files\Common Files\Microsoft Shared\OFFICE10

ចំពោះ Office 2003 => C:\Program Files\Common Files\Microsoft Shared\OFFICE11

ចំពោះ Office 2007 => C:\Program Files\Common Files\Microsoft Shared\OFFICE12

របៀបថតចម្លងឯកសារ «USP10.dll» សម្រាប់កម្មវិធី Microsoft Office 2003

- សូមចុច Mouse ខាងស្តាំ លើប៊ូតុងឯកសារ «USP10.dll» រួចសូមចុចលើ «Copy»



- សូមចូលទៅកាន់ Folder « C:\Program Files\Common Files\Microsoft Shared\OFFICE11» រួចចុច Mouse ខាងស្តាំលើផ្នែកដែលទំនេរ ហើយជ្រើសរើសយក «Paste»



- ប្រសិនបើលោកអ្នកឃើញផ្ទាំងនេះ សូមចុចលើប៊ូតុង «Yes» ជាការស្រេច